00784129 E171/1

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 24 / 02 / 2012
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

សាធារណៈ / Public

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងជំទាស់លើកទីពីរ**
**របស់ នួន ជា ចំពោះចៅក្រម CARTWRIGHT**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន

00784130

E171/1

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង*

Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

# I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១- នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ មេធាវីការពារក្តីរបស់ នួន ជា ("មេធាវីការពារក្តី") បានដាក់ *បណ្តឹងជំទាស់ចំពោះចៅក្រម* *បណ្តឹងដីតចិត្តលើកទីបីចំពោះចៅក្រម* Cartwright[1] ("បណ្តឹង")។ បណ្តឹងនេះបានសុំប្តឹងដីតចិត្តទៅតាមវិធាន៣៤.២ នៃវិធានផ្ទៃក្នុង ("វិធាន") ឬម្យ៉ាងវិញទៀត សុំឲ្យគាត់ដកខ្លួនដោយស្ម័គ្រចិត្តតាមវិធាន៣៤.១[2] ដោយមានមូលដ្ឋាននៅលើ ភាពលម្អៀងជាក់ស្តែង[3] ឬ មានការយល់ដឹងយ៉ាងសមហេតុផលអំពីភាពលម្អៀងនេះ[4]។ មូលដ្ឋានជាភ័ស្តុតាងសម្រាប់ការចោលអះអាងទាំងនេះគឺការថ្លែងនៅក្រៅអង្គជំនុំជម្រះមួយដែលបានភ្ជាប់ទៅចៅក្រម Cartwright មានក្នុងសារព័ត៌មានញូហ្សេឡែន កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១២[5] ដែលបានអាន ថាបានកើតឡើង "ដោយសារ" [6] ការថ្លែងមួយដែលក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការលើសំណុំរឿងលេខ ០០២/០១ កាលពីថ្ងៃទី៣០ ខែ មករា ឆ្នាំ២០១២[7]។

២- បណ្តឹងបច្ចុប្បន្ននេះ បានធ្វើឡើងបន្ទាប់ពីមានសំណើចំនួនពីរដែលមេធាវីការពារក្តីបានធ្វើការស្វែងរកប្តឹងដីតចិត្តចៅក្រម Cartwright ឬ ឲ្យគាត់ដកខ្លួនដោយស្ម័គ្រចិត្ត[8] ទោះជាបុគ្គលតែម្នាក់ ឬ អង្គនៃចៅក្រមទាំងមូលនៃអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ")។ សំណើទាំងពីរនេះត្រូវបានអង្គជំនុំជម្រះបដិសេធចោល[9]។

---

[1] **E171** *បណ្តឹងដីតចិត្តលើកទីបីចំពោះចៅក្រម Cartwright* ("បណ្តឹង"), ១៤ កុម្ភៈ ២០១២។

[2] **E171** បណ្តឹង, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ១។

[3] **E171** បណ្តឹង, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ១៨-២១។

[4] **E171** បណ្តឹង, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ២២។

[5] **E171** បណ្តឹង, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ២។

[6] **E171** បណ្តឹង, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ២០។

[7] **E171** បណ្តឹង, *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ២។

[8] **E54** *បណ្តឹងដីតចិត្តជាបន្ទាន់ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង,* ២៤ វិច្ឆិកា ២០១១ ("បណ្តឹងដិតចិត្តលើកទី១")និង **E137/2** *បណ្តឹងដីតចិត្តជាបន្ទាន់ចំពោះ ចៅក្រម Cartwright,* ២១ វិច្ឆិកា ២០១១("បណ្តឹងដិតចិត្តលើកទី២")។

[9] **E55/4** *សេចក្តីសម្រេចលើបណ្តឹងដីតចិត្តរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងដីតចិត្តចំពោះលោកចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGN និង ចៅក្រម យូ អូត្តារ៉ា, ឆ្នាំ,* ២៣ មីនា ២០១១ ("សេចក្តីសម្រេចលើបណ្តឹងដីតចិត្តលើកទីមួយ") និង **E137/5** *សេចក្តីសម្រេចលើបណ្តឹងដីតចិត្តចៅក្រម Silvia CARTWRIGHT,* ២ ធ្នូ ២០១១ ("សេចក្តីសម្រេចលើបណ្តឹងដីតចិត្តលើកទីពីរ")។

៣- នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា បណ្តឹងនេះគឺមិនមានអង្គសេចក្តីទាំងស្រុង។ ហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យ អង្គជំនុំជម្រះ បដិសេធបណ្តឹងនេះចោល។

## II. បណ្តឹងដឹតចិត្តនេះគួរតែត្រូវបានបដិសេធចោល

### ក. ពិសោធន៍សម្រាប់ភាពលម្អៀងជាក់ស្តែង គឺត្រូវមានទាំង បរិបទជាក់លាក់ និងទាំង ភាពតឹងរ៉ឹង
### (A. The test for actual bias is both context-specific and stringent)

៤- យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) ដែលបានរៀបរាប់ដោយមេធាវីការពារក្តី បានបង្កើតជាការវាយតម្លៃតាមផ្លូវតុលាការទៅលើពិសោធន៍សម្រាប់ភាពលម្អៀងនេះ - "ពិសោធន៍ជាអត្តនោម័ត" - គឺត្រូវមានទាំង បរិបទជាក់លាក់ និងទាំង ភាពតឹងរ៉ឹង។ នៅក្នុងករណីរបស់ *Olujić* តុលាការ ECtHR បានបញ្ជាក់អះអាងសារជាថ្មីថា ពិសោធន៍នេះមានជាប់ទាក់ទងទៅនឹង "ការខំប្រឹងខ្នះខ្នែងដើម្បីធ្វើឲ្យប្រាកដថាបាននូវការកាត់សេចក្តីដោយផ្ទាល់ខ្លួន ឬ បាននូវផលប្រយោជន៍ទៅលើចៅក្រមចំពោះមុខនៅក្នុងសំណុំរឿងជាក់លាក់ណាមួយ"[10]។ មធ្យោបាយនៅក្នុងការបង្ហាញសក្ខីកម្មសម្រាប់ភាពលម្អៀងជាក់ស្តែង មានរួមបញ្ចូល ជាឧទាហរណ៍ "ថាតើចៅក្រម ធ្លាប់បានបង្ហាញនូវអរិភាព ឬ បំណងអាក្រក់ ឬមួយក៏ធ្លាប់បានរៀបចំឲ្យគេចាត់សំណុំរឿងណាមួយឲ្យទៅគាត់ ព្រោះតែមូលហេតុផ្ទាល់ខ្លួនគាត់ដែរឬទេ?"[11]។

៥- ដូចដែលមេធាវីការពារក្តីបានទទួលស្គាល់ បន្ទុកក្នុងការបង្ហាញភស្តុតាងគឺស្ថិតនៅលើអ្នកដាក់បណ្តឹងដើម្បីច្រានចោលនូវការសន្មត់អំពីការមាន "*ភាពលំអៀងរបស់បុគ្គល* personal impartiality" ដែលមានជាប់ជាមួយនឹងចៅក្រមអាជីពណាម្នាក់[12]។ អង្គជំនុំជម្រះទាំងពីរ គឺអង្គជំនុំជម្រះនេះ និងអង្គបុរេជំនុំជម្រះ បានសំរេចថា ការសន្មតអំពីមានភាពលំអៀងមួយស្រដៀងគ្នានេះដែលមានជាប់ជាមួយចៅក្រមនានានៃ អវតក ដោយផ្អែកលើមូលដ្ឋាននៃការធ្វើសច្ចាប្រណិធាននៅពេលចូលកាន់

---

[10] *Olujić ទល់នឹង Latvia*, បណ្តឹងលេខ 22330/05 នៅតុលាការ ECtHR, សេចក្តីសម្រេច, ៥ ឧសភា ២០០៩ ត្រង់កថាខណ្ឌទី ៥៧ ("ករណីរបស់ Olujić")។

[11] *ករណីរបស់ Olujić*, កំណត់សម្គាល់*ខាងលើ* លេខ១០ ត្រង់កថាខណ្ឌទី ៥៨ ។

[12] ឯកសារលេខ **E171** ពាក្យបណ្តឹង, កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៩។ករណីរឿងក្តីរបស់ *Olujiić*, *ដូចគ្នានឹងខាងលើ កន្លែងដដែល* ត្រង់កថាខណ្ឌទី៥៨។

00784133



តំណែងរបស់ចៅក្រមទាំងនេះ និងការប្តឹងជំទាស់ចំពោះការតែងតាំងពួកគេ[13]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY នៅក្នុងសាលដីកាមួយដែលត្រូវបានមេធាវីការពារក្តីលើកយកមកសំអាងសំរាប់គាំទ្រចំពោះបណ្តឹង បានរកឃើញថាការសន្មត់អំពីមានភាពលំអៀងត្រូវបានធ្វើយុត្តិកម្មទាំងស្រុង ដោយសារចៅក្រមអាជីពទាំងឡាយអាចមានលទ្ធភាពដើម្បី "ធ្វើឲ្យគំនិតគិតគូររបស់ខ្លួនរួចផុតពីកំហុសឆ្គងទាក់ទងទៅនឹងជំនឿរបស់បុគ្គល ឬការជំរុញចិត្តឲ្យធ្វើអ្វីមួយ predisposition ដែលមិនជាប់ពាក់ព័ន្ធបាន" [14] សូម្បីតែប្រសិនជាអាចត្រូវបាន "រកឃើញភស្តុតាង" ថា ចៅក្រមណាម្នាក់ដែលធ្វើការជំនុំជម្រះលើករណីរឿងណាមួយ "បានបង្ហាញយ៉ាងច្បាស់អំពីការចូលរួមចំណែកនៅក្នុងគោលដៅ និងទិសដៅ"របស់អង្គការណាមួយដែលធ្វើការតស៊ូមតិប្រឆាំងនឹងឧក្រិដ្ឋកម្មមួយចំនួនដែលបានចោទប្រកាន់ថាជនជាប់ចោទបានប្រព្រឹត្តក៏ដោយក៏ ចៅក្រមដែលពាក់ព័ន្ធត្រូវបានសំរេចថាអាចមានលទ្ធភាពទុកចោលទៅកៀនជញ្ជាំងនូវការលំអៀងទៅម្ខាងនៅក្នុងករណីរឿងជាពិសេសណាមួយនោះដែលនៅចំពោះមុខខ្លួន ហើយធ្វើសេចក្តីសំរេចមួយដែលមានភាពលំអៀង[15]។

៦- ការពិនិត្យឡើងវិញមួយលើអង្គហេតុនានាដែលបានលើកឡើងនៅក្នុងករណីរឿងក្តីនៅក្នុងតុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR)ដែលត្រូវបានលើកយកមកធ្វើសំអាង ដោយមេធាវី បានបង្ហាញឲ្យឃើញថា សេចក្តីថ្លែងរបស់សារព័ត៌មានឬ ការធ្វើអត្ថាធិប្បាយផ្សេងៗនៅក្នុងពេលដំណើរការនីតិវិធីនៃសវនាការជំនុំជម្រះក្តីដោយចៅក្រមណាម្នាក់ដែលលើកឡើងអំពីការព្រួយបារម្ភនានាអំពីភាពលំអៀងជាក់ស្តែង បើសិនជាការធ្វើអត្ថាធិប្បាយនោះមានលក្ខណៈជាក់លាក់ ឬជាបុគ្គលដែលសំដៅប្រឆាំងនឹងជនជាប់ចោទណាម្នាក់ ហើយជាពិសេស ដែលមុតរោល ឬដេរប្រមាថ ឬ ម្យ៉ាងទៀតឈានទៅដល់ការធ្វើបុរេវិនិច្ឆ័យទៅលើបញ្ហានានាដែលជាស្នូលនៃពិរុទ្ធភាពរបស់ជនជាប់ចោទ ឬទៅលើលទ្ធផលនៃករណីរឿងក្តី។

---

[13] ឯកសារលេខ E55/4 សេចក្តីសំរេចលើបណ្តឹងសុំជំទាស់ចិត្តលើកទី១, កំណត់សំគាល់លេខ៩ *ពីខាងលើ* ត្រង់កថាខណ្ឌទី១២។ ឯកសារលេខ E137/5 សេចក្តីសំរេចលើបណ្តឹងសុំជំទាស់ចិត្ត លើកទី២, កំណត់សំគាល់លេខ៩ *ពីខាងលើ* ត្រង់កថាខណ្ឌទី១៥។ ឯកសារលេខ C11/29 សេចក្តីសំរេចលើ ពាក្យបណ្តឹងជាការប្រញាប់ សុំជំទាស់ចិត្តលោកចៅក្រម Ney Thol ដើម្បីរង់ចាំបណ្តឹងសាទុក្ខប្រឆាំងដីកាសំរេចស្តីពីឃុំខ្លួនបណ្តោះអាសន្ននៅក្នុងករណីរបស់ នួន ជា, ចុះថ្ងៃទី៤ កុម្ភៈ ២០០៨ ត្រង់កថាខណ្ឌទី ១៥-១៧។

[14] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Anto Furundžija*, សាលដីកា, សំណុំរឿងលេខ IT-95-15/1-A (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២១ កក្កដា ២០០០ ត្រង់កថាខណ្ឌទី ៤១៩៧ ("ករណីរបស់ *Furundžija* ")។

[15] "ករណីរបស់ *Furundžija ដូចគ្នានឹងខាងលើ កន្លែងដែល* ត្រង់កថាខណ្ឌទី២០០។

៧- នៅក្នុងករណីរឿងក្តីរបស់ *Olujić* តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR)បានសំរេចថា សេចក្តីថ្លែងតាមសារព័ត៌មានដោយសាមាជិកណាម្នាក់របស់ក្រុមប្រឹក្សានៃតុលាការជាតិ (NJC) អំពីសវនាការនៃប្រទេសក្រូអាស៊ីស្តីពីដំណើការនីតិវិធីខាងវិន័យប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹងបានបង្ហាញឱ្យឃើញថាមានភាពលំអៀងជាក់ស្តែង។ យោងទៅលើសេចក្តីថ្លែងរបស់អ្នកដាក់ពាក្យបណ្តឹងសមាជិកទាំងនេះបានថ្លែងថា៖

> *[...] ខ្ញុំបានឃើញពួកគេភាគច្រើនថាជារឿងកំប្លែងគួរឱ្យអស់សំណើច ដោយខ្ញុំធ្វើជាអ្នកនិពន្ធដោយខ្លួនឯង (himself???)។ សេចក្តីថ្លែងដែលបានប្រឌិតឡើងនិងដែលគ្មានអ្វីគាំទ្រទាំងនេះគឺមកពីបុរសម្នាក់ដែលជាអ្នកបានកាន់មុខងារដែលទទួលខុសត្រូវជាន់ខ្ពស់មួយចំនួននៅក្នុងតុលាការរបស់ប្រទេសក្រូអាស៊ីដែលដោយសារតែការខ្វះបទពិសោធន៍និងចំណេះដឹងនោះគាត់គឺជា តួអង្គជនបរទេសម្នាក់ (corpus alienum= a foreign body) ដែលតាមពិតមិនសក្តិសមនិងទទួលបាននូវការយកចិត្តទុកដាក់ជាពិសេសនោះឡើយ ពីព្រោះពួកគេជាកម្មសិទ្ធិរបស់ទីកន្លែងដែលពួកគេមានមានប្រភពដើមចេញមកពីទីនោះ គឺថា មកពីហាងកាហ្វេ (coffee-bars)[16]។*

៨- នៅក្នុងករណីរឿងក្តីរបស់ *Lavents* លោកចៅក្រមប្រធានអង្គជំនុំជម្រះនៃតុលាការតំបន់មួយបានធ្វើសេក្តីថ្លែងតាមសារព័ត៌មានចំនួនពីរលើកដែលកើតមានឡើងនៅក្នុងអម្លុងពេលនៃដំណើរការសវនាការជំនុំជម្រះក្តី។សេចក្តីថ្លែងលើកទីមួយ ត្រូវបានបោះពុម្ពនៅក្នុងសារព័ត៌មានប្រចាំថ្ងៃចំនួនពីរដែលក្នុងនោះមានការធ្វើអត្ថាធិប្បាយ ដូចខាងក្រោមនេះ៖

> *បើសិនជា មេធាវីការពារក្តីមានប្រាជ្ញាវៃឆ្លាតនោះ ពួកគេមុខជាធ្វើការជជែកតវ៉ាលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងហើយ។ នៅក្នុងពេលសវនាការមុខជាសំដែងអំពីការជំទាស់របស់ខ្លួននិងវែកញែកបង្ហាញឱ្យឃើញពីកំហុសឆ្គងរបស់រដ្ឋអាជ្ញាហើយ។ បើសិនជាពួកគេ មានការមិនយល់ព្រមទៅលើសាលក្រមនោះ ពួកគេអាចដាក់បណ្តឹងសាទុក្ខមួយនៅចំពោះមុខតុលាការជាន់ខ្ពស់ជាងនេះ។ ក៏ប៉ុន្តែ មេធាវីការពារក្តីបានសំរេចចិត្តលះបង់ខ្ញុំចោលដោយពិតប្រាកដណាស់ហើយពួកគេបានដាក់ពាក្យប្តឹងដឹតចិត្តមិនចេះចប់មិនចេះហើយទៅវិញ។*

[16] ករណីរឿងក្តីរបស់ *Olujic*, កំណត់សំគាល់លេខ១០ *ពីខាងដើម* ត្រង់កថាខណ្ឌទី២២។

> *[...] ពួកគេចាត់ទុកថា ជនជាប់ចោទមិនមានពិរុទ្ធភាពទេ ថាគឺរដ្ឋអាជ្ញាទេដែលជាអ្នកខុស។ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនអាចនិយាយបានទេថាតើសាលក្រមនេះ សំរេចកាត់ឲ្យមានទោស ឬ មួយក៏សំរេចលើកលែងការចោទប្រកាន់មួយផ្នែក[ ...]*[17] ។

នៅក្នុងសេចក្ដីថ្លែងតាមសារព័ត៌មានលើកទីពីរ គឺ៖ “និយាយតាមត្រង់ទៅ គឺខ្ញុំមិនយល់ទេអំពីមេធាវីការពារក្ដីនិងជនជាប់ចោទ។ ពួកគេមិនទទួលស្គាល់ថា ខ្លួនឯងថាមានទោសផង[...]”[18]។

៩- តុលាការ ECtHR បានសម្រេចថា សេចក្ដីអធិប្បាយរបស់ចៅក្រមដែលថាលោកស្រីមិនដឹងថា “សាលក្រម” នោះគឺជាសាលក្រមកាត់ទោស ឬ ឲ្យរួចខ្លួនមួយផ្នែក” បង្ហាញឲ្យឃើញនូវទស្សនៈដែលបានបង្កើតជាមុនដែលថា ការឲ្យរួចខ្លួនពេញលេញមួយ មិនអាចទៅរួចទាល់តែសោះ។ តុលាការ ECtHR បានពិចារណាថាការប្រកាសដូច្នេះមិនបានរួមបង្កើតបានជាការ “បំពេញចិត្តគុណតម្លៃជាអវិជ្ជមានយ៉ាងសាមញ្ញចំពោះករណីនោះឡើយ” ប៉ុន្តែផ្ទុយទៅវិញ វាគ្រាន់តែជាជំហរពិតប្រាកដមួយចំពោះករណីមួយរបស់អ្នកប្ដឹងដែលមិនទាន់បានសម្រេច និងអាទិភាពច្បាស់លាស់មួយសម្រាប់ការស្វែងរកពិរុទ្ធភាព[19]។

---

[17] ករណីរឿងក្ដីរបស់ *Lavents ទល់នឹង Lettonie*, តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប(EctHR) ពាក្យបណ្ដឹងលេខ No 58442/00, ‘សាលក្រម’, ជុំថ្ងៃទី២៨ កុម្ភៈ ២០០៣ ត្រង់កថាខណ្ឌទី៣០ (“ករណីរបស់ *Lavents”)* [ ការបកប្រែជាបណ្ដោះអាសន្នពីច្បាប់ដើមជាភាសាបារាំង: *D'ailleurs, s'ils étaient des gens vraiment intelligents, ils pourraient débattre les preuves qui se trouvent dans le dossier. Pendant le débat contradictoire, ils pourraient exprimer leurs objections et démontrer les erreurs du Parquet général. S'ils étaient en désaccord avec le jugement, ils pourraient former un recours devant une juridiction supérieure. Mais la défense a décidé de se débarrasser de moi par tout moyen, et les demandes en récusation s'enchaînent les unes après les autres...ils [la défense] considèrent que les accusés ne sont pas coupables, que 'accusation est fausse. Je ne puis pas encore dire aujourd'hui si 'le jugement portera condamnation ou acquittement partiel...*].

[18] ករណីរបស់ *Lavents, ដូចគ្នានឹងខាងលើកន្លែងដដែល,* ត្រង់កថាខណ្ឌទី៣១ [ការបកប្រែជាបណ្ដោះអាសន្នពីច្បាប់ដើមជាភាសាបារាំង: ...និយាយតាមត្រង់ទៅ ខ្ញុំមិនយល់ទេ អំពីមេធាវី និងជនជាប់ចោទ។ ពួកគេមិនទទួលស្គាល់ខ្លួនឯងថាមានទោសផង ...]។

[19] *Lavent,* កំណត់សម្គាល់ លេខ១៧ *ពីខាងដើម,* ត្រង់កថាខណ្ឌទី១៩ [ការបកប្រែជាបណ្ដោះអាសន្នពីឯកសារដើមជាភាសាបារាំង៖ *Aux yeux de la Cour, de telles déclarations ne constituent pas une simple « appréciation négative de la cause » du requérant, mais une véritable prise de position sur l'issue de l'affaire, avec une nette préférence pour un constat de culpabilité de l'accusé*]។

00784136



១០- ករណីរឿងក្តីរបស់ *Kyprianou* [20] ត្រូវបានមេធាវីការពារក្តីលើកយកមកសំអាង ទាក់ទងនឹងសេចក្តីថ្លែងដែលបានធ្វើឡើងដោយចៅក្រមម្នាក់នៅក្នុងពេលកំពុងដំណើរការសវនាការជំនុំជម្រះក្តី ជាជាងសំអាងលើសេចក្តីថ្លែងតាមសារព័ត៌មានទៅវិញ។ តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR)បានរកឃើញថា មានទិដ្ឋភាពចំនួនបួននៃក្រមសីលធម៌សំរាប់ចៅក្រមដែលកំពុងជាបញ្ហាបានបង្ហាញឱ្យឃើញថាមានភាពលំអៀងជាក់ស្តែង។ ទី១ គឺចៅក្រមនានាបានថ្លែងដែលកត់ត្រាចូលនៅក្នុងកំណត់ថាពួកលោកត្រូវបាន "ជេរប្រមាថយ៉ាងខ្លាំង" "ក្នុងនាមជាបុគ្គល"ដោយអ្នកដាក់ពាក្យបណ្តឹង-មានមេធាវីការពារក្តីម្នាក់ត្រូវបានចោទប្រកាន់ពីបទប្រមាថមើលងាយតុលាការ។ ទី២ ចៅក្រមទាំងឡាយបានប្រើប្រាស់ការ "និយាយដោយសង្កត់ពាក្យយ៉ាងច្បាស់ៗ"នៅក្នុងទូទាំងអម្តុពេលនៃការវិនិច្ឆ័យក្តីទាំងមូលដែលបញ្ចេញឱ្យដឹងពីអារម្មណ៍ដែលមានភាព "អាម៉ាស់ និងតក់ស្លុត" ដែល តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR) បានរកឃើញថា "មានការរត់បញ្ច្រាស់គ្នានឹងវិធីសាស្ត្រដាច់តែឯងដែលត្រូវបានរំពឹងទុកនៅក្នុងការប្រកាសផ្សេងៗរបស់តុលាការ"។ទី៣ ចៅក្រមទាំងនេះបានសំរេចផ្តន្ទាទោសអ្នកដាក់ពាក្យសុំឱ្យជាប់ពន្ធនាគារចំនួនប្រាំថ្ងៃ និងឱ្យអនុវត្តការផ្តន្ទាទោសនេះជាបន្ទាន់។ ទី៤ ចៅក្រមទាំងអស់បានរកឃើញអំពីពិរុទ្ធភាពរបស់អ្នកដាក់ពាក្យសុំពីបទប្រមាថមើលងាយតុលាការនៅក្នុងការធ្វើអន្តរសកម្មភាពនៅក្នុងដំណាក់កាលមួយកាលពីដំបូង ហើយគ្រាន់តែបានបើកឱកាសឱ្យគាត់ដើម្បីធ្វើយុត្តិកម្មថាតើហេតុអ្វីបានជាគាត់មិនគួរត្រូវបានផ្តន្ទាទោសតែប៉ុណ្ណោះ?[21]។

១១- ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថាការវាយតម្លៃមួយអំពីភាពលំអៀងជាក់ស្តែង តាមរយៈការធ្វើសេចក្តីថ្លែងតាមសារព័ត៌មានរបស់ចៅក្រមនៃអង្គជំនុំជម្រះឬការធ្វើសេចក្តីថ្លែងផ្សេងៗនៅក្នុងអម្តុងពេលសវនាការ ចាំបាច់គឺជាបរិបទដែលជាក់លាក់និងដែលតឹងតែង។ សេចក្តីថ្លែងទាំងនេះនឹងមិនបដិសេធនូវការសន្មត់ថាមានភាពលំអៀងតាមរយៈការបង្ហាញឱ្យឃើញនូវភាពលំអៀងជាក់ស្តែងនោះឡើយ លុះត្រាតែការធ្វើសេចក្តីថ្លែងបែបនេះគឺជាសេចក្តីថ្លែងដែល៖ (១)បានសំដៅយ៉ាងជាក់លាក់ និងជាបុគ្គល ប្រឆាំងនឹងជនជាប់ចោទ។ (២) មានលក្ខណៈធ្វើឱ្យក្តៅក្រហាយ ឬជេរប្រមាថ។ ឬមួយក៏ ( ៣) នាំឱ្យឈានទៅដល់ការធ្វើបុរេវិនិច្ឆ័យទៅលើបញ្ហានានាដែលជាស្នូលនៃពិរុទ្ធភាពរបស់ជនជាប់ចោទ ឬ ទៅលើលទ្ធផលនៃករណីរឿងក្តី។

[20]ករណីរឿងក្តីរបស់ *Kyprianou ទល់នឹងកោះ Cyprus*, តុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប (EctHR) ពាក្យបណ្តឹងលេខ 73797/01, 'សាលក្រម', ចុះថ្ងៃទី១៥ ធ្នូ ២០០៥ ត្រង់កថាខណ្ឌទី១២៧ ("ករណីរបស់ Kyprianou")។

[21] ករណីរឿងក្តីរបស់ *Kyprianou, ដូចគ្នានឹងខាងលើកថ្លែងរដែល* ត្រង់កថាខណ្ឌទី១៣០។

00784137



## ខ. គ្មានមូលដ្ឋានទាក់ទងនឹងភស្តុតាងនៃភាពលំអៀងជាក់ស្តែងទេ

១២- ជាការគាំទ្រចំពោះការចោទប្រកាន់អំពីមានភាពលំអៀងជាក់ស្តែង មេធាវីការពារក្តីសំណូមពរថា "នៅចំពោះមុខខ្លួន ត្រូវតែបានសន្និដ្ឋានថា ការពោលអះអាងរបស់លោកស្រីចៅក្រម Cartwright បានសំដៅទៅលើក្រុមមេធាវីការពារក្តីរបស់ នួន ជា- ប្រហែលជាក្នុងចំណោមអ្នកដទៃទៀត"[22]។ សហព្រះរាជអាជ្ញា សង្កេតឃើញថា ការធ្វើអត្ថាធិប្បាយរបស់លលោកស្រីចៅក្រម Cartwright ទាក់ទងនឹង "មេធាវីការពារក្តី"នៅក្នុងបណ្តាញផ្សាយព័ត៌មានរបស់ប្រទេស នូវែលហ្សេឡង់ គ្មានពេលណាដែលសំដៅប្រឆាំងនឹង នួន ជា ឬជាពិសេសប្រឆាំងនិងមេធាវីការពារក្តីរបស់គាត់ទាល់តែសោះ។ ចំណែកដែលមានពាក់ព័ន្ធនៃអត្ថបទបានលើកឡើង ក្នុងពាក្យពេចន៍ជាទូទៅអំពីបញ្ហាថ្មីៗមួយចំនួនដែលតុលាការបានជួបប្រទះ ក្នុងនោះរួមមានតែមិនកំរិតត្រឹមតែ ពាក្យបណ្តឹងផ្សេងៗដែលទាមទារសុំដឹតចិត្តលោកស្រីចៅក្រម Cartwright លោកប្រធានអង្គជំនុំជម្រះ និងចៅក្រមកម្ពុជានានានៃអង្គជំនុំជម្រះតែប៉ុណ្ណោះទេ។ នេះគ្រាន់តែស្មើនឹងការធ្វើសេចក្តីថ្លែងអំពីអង្គហេតុដែលទាក់ទងនឹងបញ្ហានានាដែលមាននៅក្នុងកំណត់ហេតុជាសាធារណៈប៉ុណ្ណោះ។

១៣-ជាទូទៅ សេចក្តីសង្កេតរបស់ចៅក្រម Cartwright គឺជាក់ស្តែងមាននៅក្នុងការថ្លែងរបស់គាត់ពីអង្គហេតុពាក់ព័ន្ធនឹងការស្វែងរកប្តឹងដឹតចិត្តចៅក្រម៖"វាគឺជាយុត្តិសាស្រ្តទូទៅរបស់មេធាវីការពារក្តី"។ គេអាចនឹងសន្និដ្ឋានបានថាចៅក្រម Cartwright អាចនឹងមានទស្សនៈបានល្អដែលថា គំរូយ៉ាងដដែលៗនៃសំណើសុំប្តឹងដឹតចិត្ត អាចជាផ្នែកមួយនៃការសង្កត់ទៅលើ "ការបង្អាក់" ដែលជាទូទៅបានធ្វើ ឡើងដោយក្រុមមេធាវីការពារក្តី។ ពាក់ព័ន្ធទៅនឹងយុត្តិសាស្រ្តនៃតុលាការ ECtHR ដែលមេធាវី ការពារក្តីបានជំរុញការថ្លែងបែបដូច្នេះ មិនអាចនាំឲ្យមានជាលទ្ធផលបុរេវិនិច្ឆ័យមួយនៃសំណើសុំប្តឹង ដឹតចិត្តដែលនៅមិនទាន់ដោះស្រាយ ឬ បណ្តឹងដឹតចិត្តទៅថ្ងៃខាងមុខនោះបានឡើយ សូម្បីតែពាក់ព័ន្ធ ទៅនឹងចៅក្រមម្នាក់ផ្សេងទៀតក៏ដោយ។ តាមបរិបទពាក់ព័ន្ធ នៅពេលដែលមានការបដិសេធចោលនូវបណ្តឹងដឹតចិត្ត លើកទីពីររបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងចៅក្រម Cartwright នោះ អង្គជំនុំជម្រះ (ដោយមានចៅក្រមបម្រុង Fenz ជំនួសកន្លែងចៅក្រម Cartwright) បានចាត់ជាសាធារណៈនូវសំណើរបស់ មេធាវីការពារក្តីថាមានមូលដ្ឋាននៅលើ "ការចោទប្រកាន់អំពីការប្រព្រឹត្តិខុសឆ្គងដែលពុំមានភស្តុតាងបង្ហាញ" ដោយខកខាន "ពុំបានបំពេញនូវកម្រិតលក្ខខណ្ឌតម្រូវស្តីពីភស្តុតាង" តាមវិធាន៣៤ និង "ពុំមានអង្គសេចក្តី"[23]។

---

[22]ឯកសារលេខ E171 ពាក្យបណ្តឹង, កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី២។

[23] E137/5 សេចក្តីសម្រេចលើបណ្តឹងដឹតចិត្តលើកទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ៩ ត្រង់កថាខណ្ឌទី ១៩។

១៤- បើតាមសំអាងហេតុដែលបានលើកឡើងដោយតុលាការ ECtHR ក្នុងរឿងក្តី *Lavents* វាបានបង្ហាញច្បាស់ថាទោះបី "ការថ្លែងជាសាធារណៈរបស់លោកស្រីចៅក្រម Cartwright បង្ហាញយ៉ាងច្បាស់ពីទស្សនៈមិនពេញចិត្តករណី នួន ជា" ដូចដែលបានលើកឡើងដោយមេធាវីការពារក្តីក៏ដោយ[២៤] ក៏ "ទស្សនៈមិនពេញចិត្ត" តែមួយ ដោយមិនបង្ហាញពីបុរេវិនិច្ឆ័យបែបណាមួយអំពីបញ្ហាជាមូលដ្ឋានដែលមិនទាន់ត្រូវបានសម្រេចនៅក្នុងបញ្ហានេះ ដូចជាការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ជាដើម មិនមានលក្ខណៈគ្រប់គ្រាន់ដែលនាំឲ្យមានភាពលម្អៀងឡើយ។

១៥- ដូចដែលបានបង្ហាញដោយវិធីសាស្រ្តរបស់តុលាការ ECtHR រួចមកហើយគឺថា ការវាយតម្លៃទៅលើយោបល់របស់លោកស្រីចៅក្រម Cartwright នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ គួរតែត្រូវធ្វើក្នុងបរិបទនៃសវនាការនោះ និងប្រឆាំងទៅនឹងគំរូនៃបញ្ហារៀបចំសវនាការពាក់ព័ន្ធនឹងការណ៍ដែលមេធាវីការពារក្តីងាកចេញឆ្ងាយពីដែនកំណត់នៃសំណុំរឿង ០០២/០១។ ការពិតលោកស្រីចៅក្រម Cartwright បានធ្វើអន្តរាគមន៍ភ្លាមៗដែលត្រូវបានជំទាស់កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ដោយសារលោកចៅក្រមប្រធានបានព្រមានសហមេធាវីការពារក្តីពីរដងរួចមក ហើយឲ្យកំហិតពីការតាំងសំណួររបស់ខ្លួន ត្រឹមតែបញ្ហាដែលស្ថិតក្នុងវិសាលភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ ដូចខាងក្រោម៖

> ***ស៖*** *លោកស្រី ប្រាក់ យុត តើលោកស្រីធ្លាប់ដឹងទេ ថាមានរឿងក្តី០៤ នៅតុលាការនេះ? ធ្លាប់ដឹងទេ?*
>
> *[១៤:២៦:១៦]*
>
> ***ប្រធានអង្គជំនុំ៖***
>
> *លោកស្រីមិនបាច់-- សាក្សីមិនបាច់ឆ្លើយរឿងហ្នឹង ឆ្លើយតបជាមួយនឹងមេធាវីទេ ហើយរឿងនោះមិនពាក់ព័ន្ធនឹងរឿងនេះទេ ហើយករណីឈ្មោះ អាន ហ្នឹង ក៏មិនពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/១ ដែរ។*
>
> *មេធាវីអាចបន្តសំណួរផ្សេងទៀត ហើយសូមរៀបចំនូវសំណួរណាដែលពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ។ មិនស្រេចតែចិត្តក្នុងការពន្លាតនៅក្នុងវិសាលភាពដែលនូវអ្វីដែលមិនពាក់ព័ន្ធនោះឡើយ[២៥]។*

---

[២៤] បណ្តឹងដឹតចិត្ត ឯកសារ **E171** កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌ ២០។

[២៥] ឯកសារលេខ E1/35.1ប្រតិចារឹក, ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១២ ត្រង់ទំព័រ៧៤៖៧-១៧។

-----------------------------

***ស៖*** *ដូចដែលខ្ញុំដឹង គឺថា តាអាន ហើយនិង អ៊ុម ចែម គឺជាជនសង្ស័យនៅក្នុងរឿងក្ដីទីបួន តើលោកស្រីដឹងទេ?*

***ឆ៖*** *ចាស ខ្ញុំអត់ដឹង។*

***ប្រធានអង្គជំនុំ៖***

*លោកមេធាវី យើងបានប្រាប់អម្បាញ់មិញហើយ សំណុំរឿងពាក់ព័ន្ធនឹង០៣, ០៤ គឺជារឿងមួយដោយឡែក គេរៀបចំ កំពុងតែរៀបចំ បាននឹងរៀបចំដំណើរការដាច់ដោយឡែកពីសំណុំរឿង០២។ នៅក្នុងសំណុំរឿង០២ទៀតសោត អង្គជំនុំជម្រះបានកំហិត កំណត់នូវវិសាលភាពនៃអង្គហេតុសម្រាប់ធ្វើសវនាការយ៉ាងជាក់ច្បាស់។*

*យើងគិតថាលោកមេធាវីយល់ច្បាស់ពីបញ្ហានេះ ហើយអង្គជំនុំជម្រះកំហិតកំណត់លោកសួរដេញដោលកំហិតត្រឹមតែវិសាលភាពដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង០០២/១ ដោយតាមលំដាប់លេខរៀងពីអង្គហេតុលេខតូចមកលេខធំ*[២៦] *។*

១៦- កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីបានបង្ហាញច្បាស់ថា លោកស្រីចៅក្រម Cartwright បានធ្វើអន្តរាគមន៍ដើម្បីកំហិតមិនឱ្យមានការចំណាយពេលឥតប្រយោជន៍ ពាក់ព័ន្ធនឹងការលំបាកផ្នែកបច្ចេកទេសនៃការបកប្រែ និងថា បន្ទាប់ពីការធ្វើអន្តរាគមន៍របស់លោកស្រី សហមេធាវីការពារក្ដីក៏បានលើកឡើងពីបទដ្ឋានស្ដីពីភាពលម្អៀង។ សហព្រះរាជអាជ្ញាសូមដាក់ជូននូវប្រតិចារិកពិស្ដារនៃកិច្ចដំណើរការនីតិវិធីទាំងនេះដូចខាងក្រោម៖

***ប្រធានអង្គជំនុំ៖***

*លោកមេធាវី យើងបានប្រាប់អម្បាញ់មិញហើយ សំណុំរឿងពាក់ព័ន្ធនឹង០៣, ០៤ គឺជារឿងមួយដោយឡែក គេរៀបចំ កំពុងតែរៀបចំ បាននឹងរៀបចំដំណើរការដាច់ដោយឡែកពីសំណុំរឿង០២។ នៅក្នុងសំណុំរឿង០២ទៀតសោត អង្គជំនុំជម្រះបានកំហិត កំណត់នូវវិសាលភាពនៃអង្គហេតុសម្រាប់ធ្វើសវនាការយ៉ាងជាក់ច្បាស់។*

*យើងគិតថាលោកមេធាវីយល់ច្បាស់ពីបញ្ហានេះ ហើយអង្គជំនុំជម្រះកំហិតកំណត់លោកសួរដេញដោលកំហិតត្រឹមតែវិសាលភាពដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង០០២/១ ដោយតាមលំដាប់លេខរៀងពីអង្គហេតុលេខតូចមកលេខធំ។*

***លោក ម៉ៃខល ផេសមិន៖***

---

[២៦] ឯកសារលេខ E1/35.1ប្រតិចារិក, ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១២ ត្រង់ ទំព័រទី ៧៥ កថាខណ្ឌទី៣ រហូតដល់ទំព័រ ៧៦ កថាខណ្ឌទី២០) ។

00784140



*សូមអភ័យទោសលោកប្រធាន ហេតុហ្នឹងរបស់ខ្ញុំ ប្រដាប់ស្តាប់ខ្ញុំស្តាប់អត់ទាន់ សូមអភ័យទោសស្តាប់អត់បានការសម្រេចរបស់លោកប្រធាន។*

*[១៤:២៩:៥៤]*

***ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍៖***

*ខ្ញុំនឹងប្រាប់ទៅ ជម្រាបទៅលោក លោកប្រធានបានសម្រេចពីរដងហើយថា លោកគប្បីតែតាំងសំណួរក្នុងរង្វង់នៃរឿងក្ដី០០២ វគ្គទីមួយនេះតែប៉ុណ្ណោះ។ តើលោកច្បាស់ទេប៉ុណ្ណឹង?*

***លោក ម៉ៃខល ផេសមិន៖***

*សំណួររបស់ខ្ញុំ គឺស្ថិតនៅក្នុងរង្វង់ នៅក្នុងវិសាលភាព។*

***ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍៖***

*សូមលោកកុំតតាំងជាមួយនឹងយើងខ្ញុំ។ សូមលោកបន្តទៅប្រធានបទផ្សេង។*

***លោក ម៉ៃខល ផេសមិន៖***

*ខ្ញុំសូមជំទាស់ ខ្ញុំសូមបញ្ជាក់ថានៅក្នុងរឿងក្ដីនេះ គឺថាយើងខ្ញុំយល់ថារដ្ឋាភិបាលជ្រៀតជ្រែកឬរំខានដល់រឿងក្ដី០០២ ដែលទាក់ទងនឹងកូនក្ដីរបស់ខ្ញុំផងដែរ គឺរឿងក្ដី០០២។ ខ្ញុំនឹងសុំសួរសំណួររបស់ខ្ញុំតទៅទៀត។*

***ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍៖***

*ខ្ញុំដឹងហើយថា តួនាទីរបស់លោកគឺតំណាងការពារកូនក្ដីរបស់លោក ដូច្នេះសូមលោកបន្តតាំងសំណួរនៅក្នុងបរិបទសវនាការនាថ្ងៃនេះ។ អរគុណ*[២៧] *។*

## គ. ពិសោធន៍ដើម្បីបង្ហាញឱ្យបានសមរម្យនូវភាពលម្អៀង

១៧- ដើម្បីប្ដឹងជំទាស់ចៅក្រមដោយផ្អែកលើភាពលម្អៀង មេធាវីការពារក្ដីត្រូវបង្ហាញថា “កាលៈទេសៈទាំងនេះដែលធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់ យល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង”[២៨] (“ពិសោធន៍ដោយអ្នកសង្កេតការណ៍ដែលមិនលម្អៀង”)។

[២៧] ឯកសារលេខ E1/35.1ប្រតិចារឹក, ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១២ ត្រង់ទំព័រ ៧៥ កថាខណ្ឌទី៣ រហូតលំទំព័រ ៧៦ កថាខណ្ឌទី២០) ។

[២៨] ឯកសារលេខ E55/4 *សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រមលើកទី១* កំណត់សំគាល់លេខ៩ កថាខណ្ឌទី ១១។ សូមមើលផងដែរ ឯកសារ E137/2 បណ្ដឹងជំទាស់ចៅក្រមលើកទី២ កំណត់សំគាល់លេខ៨ ត្រង់កថាខណ្ឌ ១៥។ ការធ្វើតេស្តល្បងពិសោធន៍នេះ ក៏ត្រូវបានពន្យល់ផងដែរជាការឆ្លើយតបទៅនឹងសំណួរថាតើ “បុគ្គលដែលមានហេតុផល មិនលំអៀង និងទទួលបានព័ត៌មានពេញលេញ...នូវអង្គហេតុត្រឹមត្រូវយល់ឃើញដោយសមហេតុផលថា [លោកស្រីចៅក្រម Cartwright] មាន ឬនឹងមានភាពលំអៀងក្នុងការកាត់សេចក្ដីសំណុំរឿងនេះ ដែលបើកទូលាយចំពោះការពន្យល់ឱ្យជឿតាមរយៈភស្តុតាង និងសារ

១៨- ការធ្វើតេស្តល្បងពិសោធន៍ដោយអ្នកសង្កេតការណ៍មិនលម្អៀងខុសគ្នាឆ្ងាយពីបទដ្ឋាន*តូចតាចបំផុត (de minimis)* ដែលមេធាវីការពារក្តីបានដាក់ជូនអង្គជំនុំជម្រះ។ "ការណ៍គ្រាន់តែមានអារម្មណ៍ ឬសង្ស័យថាមានភាពលម្អៀងពីជនជាប់ចោទពុំគ្រប់គ្រាន់ទេ"[២៩]។ មេធាវីការពារក្តីត្រូវបង្ហាញថា ជាទម្រង់នៃភស្តុតាង "ដែលមានមូលដ្ឋានរឹងមាំ"[៣០] ថា ដោយផ្អែកលើភាពជំនាញទាំងអស់របស់គាត់ ចៅក្រមដែលត្រូវបានគេប្តឹងជំទាស់នោះមិនអាចជៀសវាងក្នុងការបង្ហាញពីភាពមិនលម្អៀងចំពោះបញ្ហាដែលពាក់ព័ន្ធនឹងសំណុំរឿងបាន ហើយមិនអាចវិនិច្ឆ័យសំណុំរឿងដែលខ្លួនកំពុងពិចារណាឲ្យបានត្រឹមត្រូវ។ ពិសោធន៍នេះបង្កើតជារបាំងមួយយ៉ាងខ្ពស់ ដោយសារថា "ខណៈដែលភាពមិនលម្អៀងពិតប្រាកដ ឬច្បាស់លាស់របស់ចៅក្រមបានធ្វើឲ្យបាត់បង់ទំនុកចិត្តចំពោះកិច្ចការរដ្ឋបាលតុលាការនោះ ដូច្នេះគេមិនអាចដឹតចិត្តចៅក្រមដោយផ្អែកលើការចោទប្រកាន់ភាពលម្អៀងដោយគ្មានមូលដ្ឋាននោះទេ"[៣១]។

១៩- "អ្នកសង្កេតការណ៍ដែលមិនលម្អៀង" គឺជា "បុគ្គលដែលបានទទួលព័ត៌មានគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ ដោយរួមបញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពអនាគតិ ហើយអ្នកសង្កេតការណ៍នោះយល់ថា អនាគតិគឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចនានាដែលចៅក្រមត្រូវតែប្រកាន់យកឲ្យខ្ជាប់ខ្ជួន"[៣២]។ អង្គជំនុំជម្រះនេះបានពន្យល់ថា "ចំណុចចាប់ផ្តើមនៃការកំណត់ពីភាពលម្អៀងរបស់ចៅក្រមគឺជាការសន្មតជាមុនសិនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម ដោយផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងពួកគាត់

---

ណានានារបស់មេធាវីការពារក្តីដែរឬទេ"។ រឿងក្តី *Furundžija* កំណត់សំគាល់លេខ១៤*ពីខាងដើម* ត្រង់ កថាខណ្ឌ ១៨៦ ដកស្រង់ចេញពី*រឿងក្តីប្រធានាធិបតីអាហ្វ្រិកខាងត្បូង និងអ្នកឯទៀត តទល់នឹង សហភាពកីឡាបាល់ Rugby នៃប្រទេសអាហ្វ្រិកខាងត្បូង និងអ្នកឯទៀត* សាលក្រមលើពាក្យសុំបដិសេធ ឆ្នាំ 1999 (7) BCLR 725 (CC), ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៩៣។

[២៩] *រឿងក្តីរដ្ឋអាជ្ញា ទតល់នឹង Edouard Karemera និងអ្នកឯទៀត* សំណុំរឿង ICTR-98-44-T, *ដីកាសម្រេចលើបណ្តឹងដឹតចិត្តចៅក្រម និងផ្អាកកិច្ចដំណើរការនីតិវិធី ធ្វើឡើង* Joseph Nzirorera ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៥ ("*Nzirorera's Motion*")។

[៣០] រឿងក្តី *Furundžija* កំណត់សំគាល់លេខ១៤ *ពីខាងដើម* ត្រង់កថាខណ្ឌទី ១៩៧។

[៣១] បណ្តឹងរបស់ *Nzirorera* កំណត់សំគាល់លេខ២៩ *ពីខាងដើម* ត្រង់កថាខណ្ឌទី ៦។

[៣២] ឯកសារ E55/4 *សេចក្តីសម្រេចលើបណ្តឹងដឹតចិត្តលើកទី១* កំណត់សំគាល់លេខ៩ *ពីខាងដើម* ត្រង់កថាខណ្ឌទី ១២ ដកស្រង់កំណត់ត្រាពីករណីរឿងក្តីរបស់ *Furundžija* កំណត់សំគាល់លេខ១៤ *ពីខាងដើម* ត្រង់កថាខណ្ឌ ១៩០។

ជាចៅក្រមនោះ"[៣៣]។ ហេតុនេះ មេធាវីការពារក្តី នួន ជា មិនត្រឹមតែត្រូវស្វែងរកភស្តុតាងឱ្យបានគ្រប់គ្រាន់ដើម្បីដាក់បន្ទុកក្នុងនាមជាភាគីដាក់បណ្តឹងប៉ុណ្ណោះទេ តែគេត្រូវបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ដើម្បី "បង្ហាញផ្ទុយពីការសន្មតទុកជាមុនបែបនេះដែលជាលក្ខខណ្ឌកម្រិតខ្ពស់"[៣៤] ដូចបានរៀបរាប់ខាងលើ[៣៥]។

២០- នៅក្នុងរឿងក្តីរបស់ *Buscemi ដែលត្រូវបានលើកយកមកសំអាងដោយមេធាវីការពារក្តី ទាក់ទងនឹងការធ្វើសេចក្តីថ្លែងតាមសារព័ត៌មានរបស់ចៅក្រមមួយរូបដែលត្រូវបានធ្វើឡើងដើម្បីបង្ហាញឱ្យឃើញមានការបារម្ភដ៏សមហេតុផលមួយអំពីភាពលំអៀង។* ចៅក្រមទទួលបន្ទុកសវនាការលើបញ្ហាការប្រគល់សិទ្ធិចិញ្ចឹមបីបាច់ថែរក្សា (ដោយមានប្រវត្តិធ្លាប់អូសបន្លាយយូរ) បានឆ្លើយតបទៅនឹងលិខិតចំហមួយពីអ្នកដាក់ពាក្យសុំដែលបានបោះពុម្ពផ្សាយនៅក្នុងកាសែតមួយ ដោយចៅក្រមនោះបានចុះផ្សាយនូវលិខិតរបស់ខ្លួននៅក្នុងកាសែតដដែលនោះ ដោយអះអាងថា ការរៀបរាប់ពីព្រឹត្តិការណ៍របស់អ្នកដាក់ពាក្យសុំនោះពុំត្រឹមត្រូវទេ ហើយបន្ទាប់មកចៅក្រមនោះក៏បានផ្តល់ព័ត៌មានយ៉ាងពិស្តារអំពីរឿងក្តីដែលខ្លួនកំពុងពិចារណានោះ (ទោះបីពុំបានបញ្ជាក់ច្បាប់នូវព័ត៌មាននោះក៏ដោយ)។ សេចក្តីថ្លែងការណ៍តាមសារព័ត៌មានរបស់ចៅក្រមរូបនោះរួមមានយោបល់ដូចខាងក្រោម៖

> *ការលើកឡើង* [របស់អ្នកដាក់ពាក្យសុំ] *ពីព្រឹត្តិការណ៍នានាដែលពុំត្រឹមត្រូវ ពាក់ព័ន្ធនឹងកាលៈទេសៈជាសារវ័ន្តនៃរឿងក្តីនេះ* [...] *ការប្រគល់សិទ្ធិបីបាច់ថែរក្សាកុមារមិនត្រូវបានផ្តល់ឱ្យឪពុកទេ តែផ្តល់ឱ្យម្តាយវិញ។ នៅឯគេហដ្ឋានរបស់ខ្លួន ការលើកឡើងពីជម្លោះរវាងឪពុកម្តាយ និងកាលៈទេសៈដទៃទៀតដែលខ្ញុំមិនអាចពន្យល់ពិស្តារបាន កុមារីនោះបានរស់ក្នុងសភាពលំបាកលំបិន ដែលនាំឱ្យមានអំពើហិង្សា រួមទាំងអំពើហិង្សាលើរូបរាងកាយផងដែរ និងយូរៗទៅធ្វើឱ្យកុមារីនោះមាត់បង់នូវស្ថិរភាពផ្នែករាងការ និងស្មារតី។ វាជាការចាំបាច់ណាស់ដែលត្រូវយកកុមារីនោះចេញពីទីនោះ ដើម្បីនាងអាចជៀសផុតពីការគាបសង្កត់* [...][៣៦]។

២១- តុលាការ ECtHR បានសម្រេចថា សេចក្តីថ្លែងការណ៍ទាំងនោះបង្ហាញថា ចៅក្រមដែលទទួលបន្ទុក

---

[៣៣] ឯកសារ **E55/4** *សេចក្តីសម្រេចលើបណ្តឹងជំទាស់លើកទី១* កំណត់សំគាល់លេខ៩ *ពីខាងដើម* ត្រង់ថាខណ្ឌទី ១២ ។

[៣៤] ឯកសារ **E55/4** *សេចក្តីសម្រេចលើបណ្តឹងជំទាស់លើកទី១* កំណត់សំគាល់លេខ៩ *ពីខាងដើម* ត្រង់កថាខណ្ឌទី ១២។

[៣៥] សូមមើល ផ្នែក ក។

[៣៦] ករណីរឿងក្តី *Buscemi ទល់នឹង Italy* ECtHR Application No. 29569/95 សាលក្រម ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៤០ ("Buscemi")។

រឿងក្ដីនោះ "បានបង្កើតជាទស្សនៈមិនពេញចិត្តចំពោះរឿងក្ដីរបស់អ្នកដាក់ពាក្យសុំ មុនពេលចៅក្រមនោះដឹកនាំសវនាការដែលត្រូវសម្រេចសេចក្ដីលើរឿងក្ដីនេះ"[៣៧]។

**ឃ. ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញឱ្យបានសមរម្យនូវភាពលម្អៀងនោះទេ**

**២២-** ភស្តុតាងដែលត្រូវបានបង្ហាញនៅពេលនេះនៅក្នុងពាក្យបណ្ដឹងមិនបានធ្វើការបង្ហាញឱ្យឃើញពីមូលដ្ឋានណាមួយដើម្បីឱ្យអ្នកសង្កេតការណ៍ដែលមានការពិចារណាពីហេតុផលមានការបារម្ភថាលោកស្រីចៅក្រម Cartwright បានបង្កើតឱ្យមានយល់ឃើញដែលមិនអំណោយផលល្អទៅលើបញ្ហានានាដែលជាស្នូលដល់ករណីរឿងក្ដីរបស់ នួន ជា ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើរូបគាត់នោះឡើយ។

**IV. ដំណោះស្រាយដែលបានស្នើសុំ**

២៣- សម្រាប់ហេតុផលទាំងនេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសូមឱ្យច្រានចោលពាក្យសុំនេះដោយសារវាពុំមានអង្គសេចក្ដីទាល់តែសោះ។

សូមលោក លោកស្រីចៅក្រម មេត្តាទទួលយកចម្លើយតបនេះដោយគោរព។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |

[៣៧] ករណីរឿងក្ដី *Buscemi ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌ ៦៨។